**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ** **ក្រសួងផែនការ**

លេខ ១៣៦៤៣ ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ពេលវេលា និងបែបបទនៃការបញ្ជូនព័ត៌មានអត្រានុកូលដ្ឋាន

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** **រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃ២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥ ស្តីពីការបង្កើតវិទ្យាស្ថានជាតិស្ថិតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតវិទ្យាស្ថានជាតិស្ថិតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសអន្តរក្រសួងនេះ កំណត់អំពីពេលវេលា បែបបទ និងព័ត៌មានចាំបាច់ពីបញ្ជីអត្រានុកូលដ្ឋានដែលត្រូវបញ្ជូន ពីក្រសួងមហាផ្ទៃ ដែលមានអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មជាសេនាធិការ ទៅវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ឱ្យបានទៀងទាត់ ទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ក្នុងគោលបំណងដើម្បីផលិតស្ថិតិអត្រានុកូលដ្ឋាន សម្រាប់គាំទ្រដល់ការរៀបចំការងាររដ្ឋបាល និងការរៀបចំផែនការនានា។

**ប្រការ២.-**

ប្រកាសអន្តរក្រសួងនេះ មានវិសាលភាពអនុវត្តចំពោះរាល់ការបញ្ជូនព័ត៌មានអត្រានុកូលដ្ឋានដែលចាំបាច់ពីអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ទៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

**ប្រការ៣.-**

វាក្យសព្ទបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសអន្តរក្រសួងនេះ មាននិយមន័យដូចខាងក្រោម៖

- **ទិន្នន័យអត្តសញ្ញាណបុគ្គល** សំដៅដល់ព័ត៌មាននានាដែលអាចកំណត់អត្តសញ្ញាណបុគ្គលណាម្នាក់។
- **ព័ត៌មានអត្រានុកូលដ្ឋាន** សំដៅដល់ទិន្នន័យចុះបញ្ជីអត្រានុកូលដ្ឋាន រួមមានការចុះបញ្ជីកំណើតរស់ ការចុះបញ្ជីអាពាហ៍ពិពាហ៍ និងការចុះបញ្ជីមរណភាព និងមូលហេតុមរណភាព។
- **សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (API)** សំដៅដល់ច្រកចេញចូលស្តង់ដា ដែលអនុញ្ញាតឱ្យទិន្នន័យអាចផ្លាស់ប្តូរពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយផ្សេងទៀត។ ការផ្លាស់ប្តូរទិន្នន័យ គឺតម្រូវឱ្យស្របតាមលក្ខខណ្ឌដែលបានកំណត់។

## ជំពូកទី២
## បទប្បញ្ញត្តិរួម

**ប្រការ៤.-**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ មានភារកិច្ចត្រូវបញ្ជូនព័ត៌មានអត្រានុកូលដ្ឋាន ទៅវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ តាមរយៈសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (API) ដែលបានកំណត់។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ មិនត្រូវបញ្ជូនរាល់ទិន្នន័យដែលអាចកំណត់អត្តសញ្ញាណបុគ្គលបាន ដូចជា ឈ្មោះ លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល (UIC) លេខផ្ទះ លេខផ្លូវ លេខទូរសព្ទ និងអ៊ីមែលជាដើម ទៅវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការឡើយ។

## ជំពូកទី៣
## ព័ត៌មានអត្រានុកូលដ្ឋាន ពេលវេលា និងបែបបទនៃការបញ្ជូន

**ប្រការ៥.-**

ព័ត៌មានក្នុងបញ្ជីកំណើតរស់ ដែលអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ត្រូវបញ្ជូនទៅវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ រួមមាន៖

- ថ្ងៃខែឆ្នាំកំណើត
- ថ្ងៃខែឆ្នាំចុះបញ្ជី
- ថ្ងៃខែឆ្នាំកំណើតរបស់ម្ដាយ
- ថ្ងៃខែឆ្នាំកំណើតរបស់ឪពុក
- ទីកន្លែងកំណើត
- ទីកន្លែងចុះបញ្ជីកំណើត
- លំនៅឋានបច្ចុប្បន្នរបស់ម្ដាយ និង/ឬឪពុក
- ប្រភេទនៃទីកន្លែងដែលកំណើតបានកើត
- ប្រភេទកំណើត (ទោល ភ្លោះពីរ ភ្លោះបី ឬភ្លោះបួន ជាដើម)
- អ្នកផ្ដល់សេវាសម្រាលកូន
- ចំនួនកំណើតរស់ដែលម្ដាយបានសម្រាលមកទល់នឹងពេលបច្ចុប្បន្ន
- ភេទរបស់អ្នកកើត
- ទម្ងន់នៅពេលកើត
- កម្រិតវប្បធម៌របស់ម្ដាយ
- កម្រិតវប្បធម៌របស់ឪពុក
- ស្ថានភាពអាពាហ៍ពិពាហ៍របស់ម្ដាយ ឪពុក
- លេខសម្គាល់លិខិតជូនដំណឹងអំពីកំណើតរស់។

ព័ត៌មាននៅក្នុងប្រការ៥ ត្រូវផ្ដល់នៅក្នុងទម្រង់ដែលជាឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៦.-**

ព័ត៌មានក្នុងបញ្ជីអាពាហ៍ពិពាហ៍ ដែលអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ត្រូវបញ្ជូនទៅវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ រួមមាន៖

- ថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍
- ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍
- ថ្ងៃខែឆ្នាំកំណើតរបស់ប្តី
- ថ្ងៃខែឆ្នាំកំណើតរបស់ប្រពន្ធ
- លំនៅឋានបច្ចុប្បន្នរបស់ប្តី និង/ឬប្រពន្ធ
- កម្រិតវប្បធម៌របស់ប្តី
- កម្រិតវប្បធម៌របស់ប្រពន្ធ

ព័ត៌មាននៅក្នុងប្រការ៦ ត្រូវផ្តល់នៅក្នុងទម្រង់ដែលជាឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៧.-**

ព័ត៌មានក្នុងបញ្ជីមរណភាព ដែលអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ត្រូវបញ្ជូនទៅវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ រួមមាន៖

- ថ្ងៃខែឆ្នាំទទួលមរណភាព
- ថ្ងៃខែឆ្នាំចុះបញ្ជីមរណភាព
- ថ្ងៃខែឆ្នាំកំណើតរបស់មរណជន
- ទីកន្លែងចុះបញ្ជីមរណភាព
- ទីកន្លែងមរណភាព
- លំនៅឋានបច្ចុប្បន្នរបស់មរណជន
- លំនៅឋានបច្ចុប្បន្នរបស់ម្តាយ (ប្រសិនបើជាមរណភាពទារក)
- ប្រភេទនៃទីកន្លែងទទួលមរណភាព
- ភេទរបស់មរណជន
- ស្ថានភាពអាពាហ៍ពិពាហ៍របស់មរណជន
- កម្រិតវប្បធម៌របស់មរណជន
- ប្រភេទនៃមរណភាព (ប្រក្រតី ឬខុសប្រក្រតី)
- លេខកូដមូលហេតុឫសគល់នៃមរណភាព និងមូលហេតុនៃមរណភាព
- លេខសម្គាល់លិខិតជូនដំណឹងអំពីមរណភាព។

ព័ត៌មាននៅក្នុងប្រការ៧ ត្រូវផ្តល់នៅក្នុងទម្រង់ដែលជាឧបសម្ព័ន្ធទី៣ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៨.-**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ត្រូវបញ្ជូនព័ត៌មានចុះបញ្ជីកំណើតរស់ បញ្ជីអាពាហ៍ពិពាហ៍ និងបញ្ជីមរណភាពប្រចាំត្រីមាសនីមួយៗ ដូចមានចែងនៅក្នុងប្រការ៥ ប្រការ៦ និងប្រការ៧ ខាងលើ ទៅវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ មិនឱ្យលើសពីចំនួន ១៤(ដប់បួន)ថ្ងៃនៃថ្ងៃធ្វើការ នៃត្រីមាសបន្ទាប់។

**ប្រការ៩.-**

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ មានភារកិច្ចជូនដំណឹង និងផ្តល់ជូននូវរបាយការណ៍ស្ថិតិអត្រានុកូលដ្ឋានដែលបានចងក្រង ផលិត និងបោះពុម្ពរួច ទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងមហាផ្ទៃ និងក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦រោចខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងផែនការ**

**អភិសន្តិបណ្ឌិត ស សុខា** | **ប៊ិន ត្រាឈៃ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## នៃប្រកាសអន្តរក្រសួងលេខ...១៨៣៧/៤៨...ប្រក ចុះថ្ងៃទី...១១...ខែ...ធ្នូ.......ឆ្នាំ២០២៥

## ស្តីពីពេលវេលា និងបែបបទនៃការបញ្ជូនព័ត៌មានអត្រានុកូលដ្ឋាន

### ចន្លោះបំពេញទិន្នន័យសម្រាប់កំណើតរស់

| ទិន្នន័យ | និយមន័យ | ឧទាហរណ៍ និងលេខកូដ |
|---|---|---|
| ថ្ងៃខែឆ្នាំកំណើត | ថ្ងៃខែឆ្នាំជាក់លាក់ ដែលកំណើតរស់បានកើតឡើង និងគួរតែត្រូវបានបង្ហាញជាថ្ងៃ ខែ និងឆ្នាំ។ | DD/MM/YYYY |
| ថ្ងៃខែឆ្នាំចុះបញ្ជី | ថ្ងៃខែឆ្នាំជាក់ស្តែង ដែលកំណើតរស់ត្រូវបានចុះបញ្ជីនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងគួរតែត្រូវបានបង្ហាញជាថ្ងៃ ខែ និងឆ្នាំ។ | DD/MM/YYYY |
| ថ្ងៃខែឆ្នាំកំណើតរបស់ម្តាយ | ថ្ងៃខែឆ្នាំជាក់ស្តែង ដែលម្តាយ/ឪពុកបានកើត និងគួរតែត្រូវបានបង្ហាញជាថ្ងៃ ខែ និងឆ្នាំ។ | DD/MM/YYYY |
| ថ្ងៃខែឆ្នាំកំណើតរបស់ឪពុក | | |
| ទីកន្លែងចុះបញ្ជី | ទីតាំងភូមិសាស្ត្រដែលកំណើតរស់ត្រូវបានចុះបញ្ជី វាគួរតែរួមបញ្ចូលព័ត៌មានយ៉ាងហោចណាស់ មានឈ្មោះ និងលេខកូដ រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ។ | ០៨ ខេត្តកណ្តាល<br>០១ ស្រុកកណ្តាលស្ទឹង<br>២៧ ឃុំត្រពាំងវែង |
| ទីកន្លែងកំណើត | ទីតាំងភូមិសាស្ត្រដែលកំណើតរស់បានកើតឡើង វាគួរតែរួមបញ្ចូលព័ត៌មានយ៉ាងហោចណាស់ មានឈ្មោះ និងលេខកូដ រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់។ | ០៨ ខេត្តកណ្តាល<br>០១ ស្រុកកណ្តាលស្ទឹង<br>២៧ ឃុំត្រពាំងវែង |
| លំនៅឋានបច្ចុប្បន្នរបស់ម្តាយ | ទីតាំងភូមិសាស្ត្រដែលម្តាយស្នាក់នៅតាមប្រក្រតី។ ប្រសិនបើមានលំនៅឋានលើសពីមួយ ត្រូវយកកន្លែងដែលគាត់ស្នាក់នៅច្រើនជាងគេបំផុត។ គួររួមបញ្ចូលព័ត៌មានយ៉ាងហោចណាស់ មានឈ្មោះ និងលេខកូដ រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់។ | |
| ប្រភេទទីកន្លែងកំណើត | ប្រភេទទីតាំងដែលកំណើតរស់បានកើតឡើង។ បើទោះជាទៅមូលដ្ឋានសុខាភិបាល ក្នុងអំឡុង ៤៨ម៉ោង ក្រោយកើតក៏ចាត់ទុកថាកំណើតរស់បានកើតឡើងក្នុងមូលដ្ឋានសុខាភិបាលជាក់លាក់ណាមួយដែរ។ | ១= មន្ទីរពេទ្យជាតិ<br>២= មន្ទីរពេទ្យបង្អែករាជធានី/ខេត្ត<br>៣= មន្ទីរពេទ្យបង្អែកក្រុង/ស្រុក/ខណ្ឌ<br>៤= មណ្ឌលសុខភាព<br>៥= ប៉ុស្តិ៍សុខភាព<br>៦= មូលដ្ឋានសុខាភិបាលឯកជន<br>៧= ផ្ទះ<br>៨= ផ្សេងៗ សូមបញ្ជាក់។ |

| | | |
|---|---|---|
| ប្រភេទកំណើត | សំដៅលើលក្ខណៈទោល ភ្លោះ ឬពហុលក្ខណៈនៃផលិតផលនៃការពពោះ ដែលពាក់ព័ន្ធនិងរបាយការណ៍ស្ថិតិ។ | ១= កំណើតទោល<br>២= ភ្លោះពីរ<br>៣= ភ្លោះបី<br>៤= ភ្លោះបួន<br>៥= ផ្សេងៗ សូមបញ្ជាក់។ |
| អ្នកផ្តល់សេវាសម្រាលកូន | គឺជាអ្នកដែលបានជួយគាត់ អំឡុងពេលសម្រាលកូន មានដូចជា វេជ្ជបណ្ឌិត ឆ្មប ឆ្មបបុរាណ។ល។ | ១= វេជ្ជបណ្ឌិតវះកាត់<br>២= វេជ្ជបណ្ឌិត<br>៣= ឆ្មប<br>៤= ឆ្មបបុរាណ<br>៥= ផ្សេងៗ សូមបញ្ជាក់ |
| ចំនួនកំណើតរស់មកដល់បច្ចុប្បន្ន | កំណើតរស់ គឺទារកកើតរស់ដែលបានសម្រាលចេញពេញលេញ (សម្រាល ឬស្រូបទាញចេញពីផ្ទៃម្តាយ) ដោយមិនគិតដល់រយៈពេលមានផ្ទៃពោះ។ ក្រោយពីផ្តាច់ចេញពីផ្ទៃម្តាយតាមវិធីសាស្ត្រទាំងនោះ ទារកមានដង្ហើម ឬបានបង្ហាញភស្តុតាងផ្សេងទៀត ដែលបញ្ជាក់ថាមានជីវិត។ សញ្ញា ឬភស្តុតាងបញ្ជាក់ថាមានជីវិតមានដូចជា បេះដូងដើរ ជីពចរ នៃទងផ្ចិត ឬកាយវិការពិតប្រាកដនៃសាច់ដុំកំរើកដោយចេតនា ទោះបីបាន ឬមិនបានកាត់ទងផ្ចិត ឬទងសុក។ ភស្តុតាងនីមួយៗនៃកំណើតបែបនេះត្រូវបានចាត់ទុកថាទារកកើតរស់។ ដើម្បីអោយងាយស្តាប់ ក្មេងកើតរស់ គឺក្មេងកើតមកមានសំឡេងយំ។ ទារកដែលសម្រាលហើយមានសញ្ញាណាមួយបញ្ជាក់ថាមានជីវិត ទោះបីជាកើតមកហើយ ស្លាប់វិញភ្លាម ក៏ចាត់ទុកថាទារកកើតរស់ដែរ។ | សូមស្រង់ចំនួនដាក់ស្លែងចំនួន<br>០១<br>០២ |
| ភេទរបស់កូន | លក្ខណៈជីវសាស្ត្ររបស់កុមារ ដែលត្រូវបានបែងចែកជា "ប្រុស" ឬ "ស្រី"។ | ១= ប្រុស<br>២= ស្រី |
| ទម្ងន់ពេលកើត | ទម្ងន់ដំបូងរបស់ទារកទើបនឹងកើតភ្លាមៗ។ ទម្ងន់នៅពេលកើតត្រូវបានថ្លឹងក្នុងរយៈពេលមួយម៉ោងដំបូងនៃជីវិត មុនពេលការស្រកទម្ងន់យ៉ាងខ្លាំងភ្លាក្រោយពេលសម្រាលបានកើតឡើង។ | គិតជាក្រាម ឧ.២៥០០ក្រាម។ |
| កម្រិតវប្បធម៌របស់ម្តាយ | គឺជាកម្រិតអប់រំថ្នាក់ខ្ពស់បំផុតដែលគាត់បានបញ្ចប់ដោយជោគជ័យ នៅកម្រិតសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ សកលវិទ្យាល័យ ឬគ្រឹះស្ថានអប់រំផ្សេងណាមួយដែលម្តាយ/ឪពុកធ្លាប់បានចូលរៀន។ ឧទាហរណ៍ បើគាត់បានបញ្ចប់ការសិក្សាត្រឹមពាក់កណ្តាលឆ្នាំសិក្សាថ្នាក់ទី១១ ដូច្នេះកម្រិតអប់រំដែលបានបញ្ចប់ពេញលេញគឺថ្នាក់ទី១០។ | ១= មិនបានរៀន<br>២= ថ្នាក់បឋមសិក្សា<br>៣= ថ្នាក់អនុវិទ្យាល័យ<br>៤= ថ្នាក់វិទ្យាល័យ<br>៥= ថ្នាក់ឧត្តមសិក្សា<br>៦= ផ្សេងៗ សូមបញ្ជាក់។ |
| កម្រិតវប្បធម៌របស់ឪពុក | | |
| ស្ថានភាពអាពាហ៍ពិពាហ៍របស់ម្តាយ | ស្ថានភាពអាពាហ៍ពិពាហ៍បច្ចុប្បន្នរបស់ម្តាយ ពាក់ព័ន្ធនឹងច្បាប់អាពាហ៍ពិពាហ៍ ឬទំនៀមទម្លាប់របស់ប្រទេស ហើយមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសំបុត្រកំណើតនោះទេ។ | ១= មានសំបុត្រអាពាហ៍ពិពាហ៍<br>២= គ្មានសំបុត្រអាពាហ៍ពិពាហ៍ |

## ឧបសម្ព័ន្ធទី២

## នៃប្រកាសអន្តរក្រសួងលេខ...១៣៧៥៣...ប្រក ចុះថ្ងៃទី...១១...ខែ...ក្ន...........ឆ្នាំ២០២៥

## ស្តីពីពេលវេលា និងបែបបទនៃការបញ្ជូនព័ត៌មានអត្រានុកូលដ្ឋាន

## ចន្លោះបំពេញទិន្នន័យសម្រាប់អាពាហ៍ពិពាហ៍

| ទិន្នន័យ | និយមន័យ | ឧទាហរណ៍ និងលេខកូដ |
|---|---|---|
| ថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ | ថ្ងៃខែឆ្នាំជាក់លាក់ ដែលអាពាហ៍ពិពាហ៍មានសុពលភាពតាមផ្លូវច្បាប់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន បានកើតឡើង និងគួរតែត្រូវបានបង្ហាញជាថ្ងៃ ខែ និងឆ្នាំ។ | DD/MM/YYYY |
| ថ្ងៃខែឆ្នាំកំណើតរបស់ប្តី<br>ថ្ងៃខែឆ្នាំកំណើតរបស់ប្រពន្ធ | ថ្ងៃខែឆ្នាំជាក់ស្តែង ដែលកូនកម្លោះ/កូនក្រមុំបានកើត និងគួរតែត្រូវបានបង្ហាញជាថ្ងៃ ខែ និងឆ្នាំ។ | DD/MM/YYYY |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ | ទីតាំងភូមិសាស្ត្រ ដែលអាពាហ៍ពិពាហ៍មានសុពលភាពតាមផ្លូវច្បាប់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ហើយគួររួមបញ្ចូលព័ត៌មានយ៉ាងហោចណាស់ មានឈ្មោះ និងលេខកូដ រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់។ | ០៨ ខេត្តកណ្តាល<br>០១ ស្រុកកណ្តាលស្ទឹង<br>០៧ ឃុំត្រពាំងវែង |
| លំនៅឋានរបស់ប្តី<br>លំនៅឋានរបស់ប្រពន្ធ | ទីតាំងភូមិសាស្ត្រដែលកូនកម្លោះ/កូនក្រមុំស្នាក់នៅតាមប្រក្រតី។ ប្រសិនបើមានលំនៅឋានលើសពីមួយ ត្រូវយកកន្លែងដែលគាត់ស្នាក់នៅច្រើនជាងគេបំផុត។ គួររួមបញ្ចូលព័ត៌មានយ៉ាងហោចណាស់ មានឈ្មោះ និងលេខកូដ រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់។ | |
| កម្រិតវប្បធម៌របស់កូនកម្លោះ<br>កម្រិតវប្បធម៌របស់កូនក្រមុំ | គឺជាកម្រិតអប់រំថ្នាក់ខ្ពស់បំផុតដែលគាត់បានបញ្ចប់ដោយជោគជ័យ នៅកម្រិតសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ សកលវិទ្យាល័យ ឬគ្រឹះស្ថានអប់រំផ្សេងណាមួយដែលគាត់ធ្លាប់បានចូលរៀន។ ឧទាហរណ៍ បើគាត់បានបញ្ចប់ការសិក្សាត្រឹមពាក់កណ្តាលឆ្នាំសិក្សាថ្នាក់ទី១១ ដូច្នេះកម្រិតអប់រំដែលបានបញ្ចប់ពេញលេញគឺថ្នាក់ទី១០។ | ១= មិនបានរៀន<br>២= ថ្នាក់បឋមសិក្សា<br>៣= ថ្នាក់អនុវិទ្យាល័យ<br>៤=ថ្នាក់វិទ្យាល័យ<br>៥= ថ្នាក់ឧត្តមសិក្សា<br>៦= ផ្សេងៗ សូមបញ្ជាក់។ |

## ឧបសម្ព័ន្ធទី៣

## នៃប្រកាសអន្តរក្រសួងលេខ...១៧៧៥៣...ប្រក ចុះថ្ងៃទី...១១...ខែ...ធ្នូ.......ឆ្នាំ២០២៥

## ស្តីពីពេលវេលា និងបែបបទនៃការបញ្ជូនព័ត៌មានអត្រានុកូលដ្ឋាន

## ចន្លោះបំពេញទិន្នន័យសម្រាប់មរណភាព

| ទិន្នន័យ | និយមន័យ | ឧទាហរណ៍ និងលេខកូដ |
|---|---|---|
| ថ្ងៃខែឆ្នាំទទួលមរណភាព | ថ្ងៃខែឆ្នាំជាក់លាក់ ដែលមរណភាពបានកើតឡើង និងគួរតែត្រូវបានបង្ហាញជាថ្ងៃ ខែ និងឆ្នាំ។ | DD/MM/YYYY |
| ថ្ងៃខែឆ្នាំចុះបញ្ជី | ថ្ងៃខែឆ្នាំជាក់ស្តែង ដែលមរណភាពត្រូវបានចុះបញ្ជីនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងគួរតែត្រូវបានបង្ហាញជាថ្ងៃ ខែ និងឆ្នាំ។ | DD/MM/YYYY |
| ថ្ងៃខែឆ្នាំកំណើតរបស់មរណជន | ថ្ងៃខែឆ្នាំជាក់ស្តែង ដែលមរណជនបានកើត និងគួរតែត្រូវបានបង្ហាញជាថ្ងៃ ខែ និងឆ្នាំ។ | DD/MM/YYYY |
| ទីកន្លែងចុះបញ្ជី | ទីតាំងភូមិសាស្ត្រដែលមរណភាពបានចុះបញ្ជី វាគួរតែរួមបញ្ចូលព័ត៌មានយ៉ាងហោចណាស់ មានឈ្មោះ និងលេខកូដ រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ។ | ០៨ ខេត្តកណ្តាល<br>០១ ស្រុកកណ្តាលស្ទឹង<br>២៧ ឃុំត្រពាំងវែង |
| ទីកន្លែងមរណភាព | ទីតាំងភូមិសាស្ត្រដែលមរណភាពបានកើតឡើង គួររួមបញ្ចូលព័ត៌មានយ៉ាងហោចណាស់ មានឈ្មោះ និងលេខកូដ រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់។ | |
| លំនៅឋានបច្ចុប្បន្នរបស់មរណជន | ទីតាំងភូមិសាស្ត្រដែលគាត់ស្នាក់នៅតាមប្រក្រតី។ ប្រសិនបើមានលំនៅឋានលើសពីមួយ ត្រូវយកកន្លែងដែលគាត់ស្នាក់នៅច្រើនជាងគេបំផុត។ គួររួមបញ្ចូលព័ត៌មានយ៉ាងហោចណាស់ មានឈ្មោះ និងលេខកូដ រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់។ | |
| លំនៅឋានបច្ចុប្បន្នរបស់ម្តាយ (សម្រាប់មរណជនជាទារក ក្រោម១ឆ្នាំ) | | |
| ប្រភេទទីកន្លែងទទួលមរណភាព | ប្រភេទទីតាំងដែលមរណភាពបានកើតឡើង។ | ១= មន្ទីរពេទ្យជាតិ<br>២= មន្ទីរពេទ្យបង្អែករាជធានី/ខេត្ត<br>៣= មន្ទីរពេទ្យបង្អែកក្រុង/ស្រុក/ខណ្ឌ<br>៤= មណ្ឌលសុខភាព<br>៥= ប៉ុស្តិ៍សុខភាព<br>៦= មូលដ្ឋានសុខាភិបាលឯកជន<br>៧= ផ្ទះ<br>៨= ផ្សេងៗ សូមបញ្ជាក់។ |

| | | |
|---|---|---|
| ភេទរបស់មរណជន | លក្ខណៈជីវសាស្ត្ររបស់មរណជន ដែលត្រូវបានបែងចែកជា "ប្រុស" ឬ "ស្រី"។ | ១= ប្រុស<br>២= ស្រី |
| ស្ថានភាពអាពាហ៍ពិពាហ៍របស់មរណជន | ស្ថានភាពរបស់មរណជន ពាក់ព័ន្ធនឹងច្បាប់អាពាហ៍ពិពាហ៍ ឬទំនៀមទម្លាប់របស់ប្រទេស។ | ១= នៅលីវ<br>២= រៀបការហើយ (បានចុះបញ្ជី)<br>៣= មេម៉ាយប្ដីស្លាប់<br>៤= ពោះម៉ាយប្រពន្ធស្លាប់<br>៥= មេម៉ាយលែងលះគ្នា<br>៦=ពោះម៉ាយលែងលះគ្នា<br>៧=កំពុងរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្ដីប្រពន្ធ |
| កម្រិតវប្បធម៌របស់មរណជន | គឺជាកម្រិតអប់រំថ្នាក់ខ្ពស់បំផុតដែលមរណជនបានបញ្ចប់ដោយជោគជ័យ នៅកម្រិតសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ សកលវិទ្យាល័យ ឬគ្រឹះស្ថានអប់រំផ្សេងណាមួយដែលគាត់ធ្លាប់បានចូលរៀន។ ឧទាហរណ៍ បើគាត់បានបញ្ចប់ការសិក្សាត្រឹមពាក់កណ្ដាលឆ្នាំសិក្សាថ្នាក់ទី១១ ដូច្នេះកម្រិតអប់រំដែលបានបញ្ចប់ពេញលេញគឺថ្នាក់ទី១០។ | ១= មិនបានរៀន<br>២= ថ្នាក់បឋមសិក្សា<br>៣= ថ្នាក់អនុវិទ្យាល័យ<br>៤=ថ្នាក់វិទ្យាល័យ<br>៥= ថ្នាក់ឧត្តមសិក្សា<br>៦= ផ្សេងៗ សូមបញ្ជាក់។ |
| មូលហេតុមរណភាព | មូលហេតុនៃមរណភាពត្រូវបានកំណត់ថាជា (ក) ជំងឺ ឬរបួសស្នាម ដែលមានប្រភពពីលំដាប់លំដោយនៃព្រឹត្តិការណ៍មួយចំនួន ដោយព្រឹត្តិការណ៍ទាំងនោះបណ្ដាលឱ្យមរណភាពមួយកើតឡើងដោយផ្ទាល់ ឬ (ខ) ស្ថានភាពនៃគ្រោះថ្នាក់ ឬអំពើហិង្សាដែលបានបង្កឱ្យមានរបួសស្នាមហួតដល់ស្លាប់។ | ចន្លោះសម្រាប់បំពេញទិន្នន័យនេះគួរបញ្ចូល មូលហេតុមរណភាពដោយយោងទៅតាម ការចាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ (ICD) ក្នុងទម្រង់ជាអត្ថបទ និងកូដ ICD។ |
| លក្ខណៈនៃមរណភាពដែលកំណត់ដោយសាមញ្ញ | លក្ខណៈនៃមរណភាពដែលត្រូវបានកំណត់ដោយសាមញ្ញ បែងចែករវាងមរណភាពប្រក្រតី និងមរណភាពខុសប្រក្រតី។ | ប្រក្រតី ឬខុសប្រក្រតី |
| លក្ខណៈនៃមរណភាពពេញលេញ | លក្ខណៈនៃមរណភាព ពន្យល់អំពីស្ថានភាពដែលមរណភាពមួយបានកើតឡើង។ | ជំងឺ គ្រោះថ្នាក់ ការបង្កគ្រោះថ្នាក់ចំពោះខ្លួនឯងដោយចេតនា/អត្តឃាត ការបំពានរាងកាយ អន្តរាគមន៍តាមផ្លូវច្បាប់ សង្គ្រាម មិនអាចកំណត់បាន រង់ចាំការស៊ើបអង្កេត មិនដឹង។ |